# ការអញ្ជើញចូលរួមបង្ហាញចំណាប់អារម្មណ៍

## ជំនួយវិនិយោគហេដ្ឋារចនាផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ នៃកម្មវិធី CAP-RED (ជុំទី ១)

កម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ ហៅកាត់ថា CAP-RED គឺជាកម្មវិធីអភិវឌ្ឍន៍របស់ប្រទេសអូស្ត្រាលីដែលធ្វើការជាមួយ រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍នានា និងវិស័យឯកជន ដើម្បីគាំទ្រដល់ផ្នែកខាងក្រោមនេះ៖

១. បរិវត្តកម្មវិស័យកសិកម្ម
២. ពាណិជ្ជកម្ម ការវិនិយោគ និងការអភិវឌ្ឍន៍សហគ្រាស
៣. សេវាហេដ្ឋារចនាសម្ព័ន្ធ។

កម្មវិធី CAP-RED កំពុងបើកជុំផ្តល់ជំនួយជុំបូងរបស់ខ្លួនដល់ប្រតិបត្តិករទឹកស្អាតតាមបំពង់ឯកជន និងអ្នកវិនិយោគផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ ក្នុងខេត្ត **កំពង់ធំ កំពង់ឆ្នាំង** និង **ខេត្តតាកែវ**។ ការផ្តល់ជំនួយនេះ រួមមាន ជំនួយហិរញ្ញវត្ថុសម្រាប់ការវិនិយោគ និងជំនួយបច្ចេកទេស សម្រាប់ការសាងសង់និងពង្រីក ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ពួកគេ នៅក្នុងតំបន់សេវាកម្មដែលមិនមានភាពទាក់ទាញគ្រប់គ្រាន់សម្រាប់ការវិនិយោគ។

ទាំងនេះ ជាជំនួយឥតសំណង ហើយត្រូវបានផ្តល់ជូនចំពោះ (១) ប្រតិបត្តករទឹកស្អាតតាមបំពង់ឯកជន ដែលបានទទួលបានប្រកាសអនុញ្ញាតរយៈពេល 20 ឆ្នាំ ពី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង (២) អ្នកវិនិយោគផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ដែលទទួលបានគោលការណ៍អនុញ្ញាតក្នុងការសិក្សាសមិទ្ធិលទ្ធភាព ពី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលស្ថិតនៅក្នុងខេត្ត **កំពង់ធំ កំពង់ឆ្នាំង** និង **ខេត្តតាកែវ** ។

ប្រិតបត្តករ និងអ្នកវិនិយោគដែលចាប់អារម្មណ៍ដាក់ពាក្យស្នើសុំជំនួយ អាចស្នើសុំ និងដាក់ពាក្យតាមរយៈ អ៊ីមែល *infor@capred.org* ឬតេឡេក្រាមលេខ **០១២ ៨១៧ ៨២៩**។

កម្មវិធី CAP-RED សូមអញ្ជើញប្រតិបត្តករទឹកស្អាតតាមបំពង់ឯកជន និងអ្នកវិនិយោគផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ទាំងអស់ ដែលចាប់អារម្មណ៍ស្នើសុំជំនួយ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយព័ត៌មានលម្អិត នៅមន្ទីរឧ.វ.ប.ន. នៃខេត្តទាំង៣។ កម្មវិធី CAP-RED លើកទឹកចិត្តឲ្យ ទាំងស្វាមីនិងទាំងភរិយាឲ្យចូលរួមក្នុងសិក្ខសាលានេះ។

ទីតាំង និងកាលបរិច្ឆេទនៃសិក្ខាសាលាផ្សព្វផ្សាយព័ត៌មានលម្អិត៖

- មន្ទីរឧ.វ.ប.ន. ខេត្តកំពង់ធំ ៖ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០២២ វេលាម៉ោង ៩ ដល់ ១១:00 ព្រឹក
- មន្ទីរឧ.វ.ប.ន. ខេត្តកំពង់ឆ្នាំង ៖ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០២២ វេលាម៉ោង ៩ ដល់ ១១:00 ព្រឹក
- មន្ទីរឧ.វ.ប.ន. ខេត្តតាកែវ ៖ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០២២ វេលាម៉ោង ៩ ដល់ ១១:00 ព្រឹក

ថ្ងៃផុតកំណត់នៃការដាក់ពាក្យស្នើសុំជំនួយ៖ **ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២២**

ទំនាក់ទំនងព័ត៌មានលម្អិត៖ 012 817 829 ឬអ៊ីមែល info@capred.org

CAP-RED is funded by the Australian Government and implemented by Cowater International.

.

Address: The iCON Professional Building, 216 Preah Norodom Blvd (41), Phnom Penh
Email: info@capred.org
Tel: 012 817 829